ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

អគ្គិសនីកម្ពុជា
គណៈកម្មាធិការលទ្ធកម្ម
លេខ: ..... PC.អក

សេចក្តីជូនដំណឹង
ស្តីពី

ការងារផ្គត់ផ្គង់សម្ភារនិងឈ្នួលពលកម្ម សាងសង់ខ្សែកាបកប់ដី 22kV ចំនួន ០១ ទ្វារចេញ ដើម្បីជួយបង្កើនសមត្ថភាពផ្គត់ផ្គង់ថាមពលអគ្គិសនី ជូន អគ្គិសនីត្បូងឃ្មុំ

អគ្គិសនីកម្ពុជាសូមជូនដំណឹងដល់បណ្តាក្រុមហ៊ុន/សហគ្រាស (គិតទាំងសហគ្រាសឯកត្តបុគ្គល) ទាំងអស់ដែលបានចុះបញ្ជីត្រឹមត្រូវក្នុងព្រះរាជាណាចក្រកម្ពុជាឲ្យបានជ្រាបថា ៖ អគ្គិសនីកម្ពុជានឹងដាក់ឱ្យដេញថ្លៃជាសាធារណៈ ដើម្បីជ្រើសរើសអ្នកទទួលការងារផ្គត់ផ្គង់សម្ភារនិងឈ្នួលពលកម្ម សាងសង់ខ្សែកាបកប់ដី 22kV ចំនួន ០១ ទ្វារចេញ ដើម្បីជួយបង្កើនសមត្ថភាពផ្គត់ផ្គង់ថាមពលអគ្គិសនី ជូន អគ្គិសនីត្បូងឃ្មុំ ។

អគ្គិសនីកម្ពុជាបានរៀបចំឯកសារសម្រាប់ក្រុមហ៊ុន/សហគ្រាសបំពេញដើម្បីចូលរួមដេញថ្លៃ ។ ឯកសារដេញថ្លៃ មានដាក់លក់នៅអង្គភាពលទ្ធកម្មអគ្គិសនីកម្ពុជាដែលមានអាសយដ្ឋាន អាគារលេខ ២ ផ្លូវព្រះយុគន្ធរ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ ចាប់ពី ថ្ងៃទី ២៤ ខែ ធ្នូ ឆ្នាំ ២០១៩ តទៅរៀងរាល់ម៉ោងធ្វើការ (ទូរស័ព្ទទាក់ទងលេខ៖ 023 67 66 007 និង Website : www.edc.com.kh) ។

ឯកសារដេញថ្លៃដែលបានបំពេញរួច ត្រូវប្រគល់ជូនអង្គភាពលទ្ធកម្ម យ៉ាងយូរបំផុតត្រឹម ថ្ងៃទី ២៨ ខែ មករា ឆ្នាំ ២០២០ វេលាម៉ោង ១៤:00 ។

ការបើកសំណើដេញថ្លៃ នឹងប្រព្រឹត្តទៅនៅអង្គភាពលទ្ធកម្ម តាមអាសយដ្ឋាន ខាងលើ វេលាម៉ោង ១៥:00 ថ្ងៃទី ២៨ ខែ មករា ឆ្នាំ ២០២០ ។

ក្រុមហ៊ុន/សហគ្រាសដែលមានសម្ព័ន្ធភាពជាមួយគ្នា ឬមានប្រភពតែមួយ អាចដាក់សំណើដេញថ្លៃបានតែមួយគត់ ។

ក្រុមហ៊ុន/សហគ្រាសដែលមានបំណងចូលរួមដេញថ្លៃ សូមអញ្ជើញទាក់ទងជាមួយអង្គភាពលទ្ធកម្ម ដើម្បីទិញឯកសារដេញថ្លៃ និងសាកសួរព័ត៌មាន ដែលទាក់ទងនឹងការដេញថ្លៃនេះ ។

ថ្ងៃ ខែ ឆ្នាំ កុរ ឯកស័ក ព.ស២៥៦៣
រាជធានីភ្នំពេញ, ថ្ងៃទី ១៨ ខែ ធ្នូ ឆ្នាំ ២០១៩
ត. ប្រធានគណៈកម្មាធិការលទ្ធកម្ម

ឃាង ឆ្ងួច

ចម្លងជូន ៖
-អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ
-អង្គភាពប្រឆាំងអំពើពុករលួយ
-ឯកសារ-កាលប្បវត្តិ